រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

អត្ថបទសិក្សា ទី ៨

"ដំណឹងល្អបំផុត"



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ការប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត

«បងប្អូន និង ចាស់ទុំទាំងអស់គ្នាអើយ សូមស្តាប់ពាក្យដោះសារបស់ខ្ញុំសិន ! » ។ កាលពួកគេឮលោកប៉ូលមានប្រសាសន៍ជាភាសាហេប្រឺដូច្នេះ គេរឹតតែសៀមសាត់ថែមទៀត ។ លោកប៉ូលមានប្រសាសន៍ថា÷ «ខ្ញុំជាជនជាតិយូដា កើតនៅក្រុងតាសុសក្នុងស្រុកស៊ីលីស៊ី ។ ប៉ុន្តែ ខ្ញុំបានមករស់នៅក្រុងយេរូសាឡឹមនេះតាំងពីកុមារ ហើយខ្ញុំបានទទួលការអប់រំតាមវិន័យនៃបុព្វបុរសរបស់យើងយ៉ាងតឹងរ៉ឹងពីសំណាក់លោកកាម៉ាលីអែល ។ ខ្ញុំបានខ្នះខ្នែងបំរើព្រះជាម្ចាស់ ដូចបងប្អូនទាំងអស់គ្នានៅថៃនេះដែរ ។

ខ្ញុំធ្លាប់បៀតបៀនអស់អ្នក ដែលដើរតាមមាគ៌ារបស់ព្រះអម្ចាស់រហូតដល់សម្លាប់គេ ហើយចាប់ចងមនុស្សប្រុសស្រីយកទៅឃុំឃាំងទៀតផង ។ ដូចមានលោកមហាបូជាចារ្យ និងក្រុមព្រឹទ្ធាចារ្យជាសាក្សីស្រាប់ ។ ខ្ញុំបានទទួលលិខិតពីលោកទាំងនោះយកទៅជូនបងប្អូននៅក្រុងដាម៉ាស ដ្បិតខ្ញុំទៅទីនោះ ដើម្បីចាប់ចងពួកអ្នកដែលដើរតាមមាគ៌ានេះ យកមកធ្វើទោសនៅក្រុងយេរូសាឡឹម ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ពេលខ្ញុំកំពុងតែធ្វើដំណើរទៅជិតដល់ក្រុងដាម៉ាស ប្រមាណជាថ្ងៃត្រង់ ស្រាប់តែមានពន្លឺមួយដ៏ភ្លឺត្រចះត្រចង់ ចាំងពីផ្ទៃមេឃមកជុំវិញខ្ញុំ ។ ខ្ញុំក៏ដួល ហើយឮសំឡេងមួយពោលមកខ្ញុំថា"*សាអ៊ូលអើយ សាអ៊ូល ! ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំដូច្នេះ ?* ខ្ញុំបានសួរវិញថា÷ "លោកម្ចាស់អើយ តើលោកជានរណា ?" ។ សំឡេងនោះឆ្លើយមកខ្ញុំថា÷ *"ខ្ញុំជាយេស៊ូ អ្នកស្រុកណាសារ៉ែត ដែលអ្នកកំពុងតែបៀតបៀន"* ។

រីឯអស់អ្នកដែលធ្វើដំណើរជាមួយខ្ញុំ ក៏បានឃើញពន្លឺនោះដែរ តែមិនបានឮព្រះសូរសៀងទេ ។

ខ្ញុំក៏សួរថា÷"ព្រះអម្ចាស់អើយ តើទូលបង្គំ ត្រូវធ្វើដូចម្តេច ?"។ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា÷ *"ចូរក្រោកឡើង ទៅក្រុងដាម៉ាសទៅ នៅទីនោះ គេនឹងប្រាប់អ្នកអំពីកិច្ចការទាំងប៉ុន្មានដែលព្រះជាម្ចាស់បង្គាប់អោយអ្នកធ្វើ"* ។

ដោយខ្ញុំពុំអាចមើលអ្វីឃើញ ព្រោះតែពន្លឺរស្មីដ៏រុងរឿងនោះ អស់អ្នក ដែលនៅជាមួយខ្ញុំ បានដឹកដៃនាំខ្ញុំទៅក្រុងដាម៉ាស ។ នៅក្រុងនោះមានបុរសម្នាក់ឈ្មោះអណានាញ៉ាស ជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ត្រឹមត្រូវតាមវិន័យ ហើយជនជាតិយូដានៅក្រុងដាម៉ាសគោរពរាប់អានគាត់គ្រប់ៗគ្នា ។ គាត់មកឈរជិតខ្ញុំ ហើយពោលថា÷ "*បងសាអ៊ូលអើយ សូមឱ្យបងមើលឃើញវិញចុះ!*" ។

រំពេចនោះ ភ្នែកខ្ញុំក៏ភ្លឺឡើង ហើយខ្ញុំមើលឃើញគាត់ ។ គាត់មានប្រសាសន៍ថា÷ "ព្រះនៃបុព្វបុរសរបស់យើង បានជ្រើសរើសបងដើម្បីអោយបងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ អោយបងបានឃើញព្រះដ៏សុចរិត និងអោយបងបានឮព្រះបន្ទូលរបស់ព្រះអង្គផ្ទាល់តែម្តង ។ ដ្បិតបងនឹងធ្វើជាបន្ទាល់របស់ព្រះអង្គនៅមុខមនុស្សទាំងអស់ អំពីហេតុការណ៍ ដែលបងបានឃើញ និងអំពីសេចក្តីដែលបងបានឮ ។ ដូច្នេះ តើបងនៅបង្អែរបង្អង់ដល់កាលណាទៀត សូមក្រោកឡើង ទទួលពិធីជ្រមុជទឹក ហើយអង្វររកព្រះនាមព្រះអង្គទៅ ដើម្បីព្រះអង្គលាងបាបអោយ" » ។

(កិច្ចការ ២២)

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- និយាយប្រាប់គ្រួសាររបស់អ្នកពីការថ្វាយខ្លួនរបស់លោកប៉ូល ។
- ទទួលពិធីជ្រមុជទឹក ជាមួយអស់អ្នកដែលទទួលជឿក្នុងក្រុមគ្រួសាររបស់អ្នក ។ (បើសិនជាពីមុន អ្នកបានទទួលពិធីជ្រមុជទឹកជាគ្រីស្តជនហើយ តែក្រោយមក ងាកចេញពីព្រះជាម្ចាស់វិញ រួចពេលនេះ អ្នកមានបំណងចង់ដើរតាមព្រះជាម្ចាស់ជាថ្មីទៀតនោះ អ្នកត្រូវលន់តួបាប និង ឈប់ប្រព្រឹត្តអំពើបាបដែលអ្នកធ្លាប់ប្រព្រឹត្ត ចំពោះខ្លួនអ្នកផ្ទាល់ និងអ្នកដទៃ ហើយត្រូវទុកចិត្តថាព្រះជាម្ចាស់ លើកលែងទោសអោយអ្នក) ។ ត្រូវអរព្រះគុណព្រះយេស៊ូ ដែលទ្រង់បានអត់ទោសរាល់អំពើបាបអ្នក ហើយទូលសូមឱ្យព្រះអង្គជួយអ្នកអោយកែប្រែ និងកសាងមេត្រីភាពដែលស្និទ្ធស្នាល និងពេញលេញជាមួយព្រះអង្គ នៅក្នុងជីវិតរបស់អ្នកជាថ្មីទៀត ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

នេះជាសេចក្តីដែលសាវ័កប៉ូលរៀបរាប់ពីការថ្វាយខ្លួនរបស់គាត់ ។

តើលោកប៉ូលមានឈ្មោះមួយទៀតថាដូចម្តេច ? ស _____

តើមុនពេលថ្វាយខ្លួន លោកប៉ូលធ្វើអាក្រក់ដូចម្តេចខ្លះ ?

_____

_____

តើភ្នែកគាត់ទៅជាយ៉ាងដូចម្តេច ?

_____

តើអ្នកណាបានអធិស្ឋានអោយភ្នែកគាត់មើលឃើញវិញ ?

_____

នៅចុងបញ្ចប់សេចក្តីរៀបរាប់របស់លោកប៉ូល តើអណាញ៉ាសប្រាប់អោយលោកប៉ូលធ្វើដូចម្តេច ?

_____

_____

© Project WorldReach © SEAN

លោកសូលទទួលពិធីជ្រមុជទឹក ដើម្បីធ្វើតាមពាក្យរបស់អណា-ញ៉ាស ។ ក្រោយមក គាត់ក៏ចាប់ផ្តើមនាំអ្នកឯទៀតមកថ្វាយខ្លួន និងប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត ។

ព្រះគ្រីស្តបង្គាប់អោយយើងបង្កើតសាវ័ក ដែលប្រតិបត្តិតាមគ្រប់សេចក្តីដែលព្រះអង្គបានបង្គាប់ ។ (សូមសិក្សាសេចក្តីបង្គាប់ទាំងនេះ ដោយទន្ទេញអោយចាំស្មាត់ ។ សូមគួសបន្ទាត់ពីក្រោមសេចក្តីណាដែលអ្នកត្រូវប្រតិបត្តិតាម ឱ្យបានប្រសើរឡើង។) ។ សេចក្តីបង្គាប់ខ្លះរបស់ព្រះអង្គសំរាប់សាវ័កព្រះអង្គ គឺ :

- កែប្រែចិត្តគំនិត និងជឿ (ម៉ាកុស ១:១៥) ។
- ទទួលពិធីជ្រមុជទឹក (ម៉ាកុស ១៦:១៦) ។
- ស្រឡាញ់ព្រះអម្ចាស់ និងមនុស្សឯទៀតៗ (ម៉ាថាយ ២២:៣៧-៣៩) ។
- ចូលរួមធ្វើពិធីកាច់នំប៉័ង (លូកា ២២:១៧-២០) ។
- អធិស្ឋាន និងអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាចំណីអាហារខាងព្រលឹងវិញ្ញាណ (ម៉ាថាយ ៤:៤, ៦:៥-១៣)។

- អោយ (ដាក់ដង្វាយ) (ម៉ាថាយ ៦:១៩-២០) ។
- ផ្សាយដំណឹងល្អ (ផ្សព្វផ្សាយដំណឹងល្អដល់មនុស្សរហូតដល់គេប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត) (ម៉ាថាយ ២៨:១៨-២០) ។

ខ សំរាប់ទន្ទេញ

«ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក » ។

(ម៉ាថាយ ២៨:១៨-២០)